ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: 260..... សប្រក.កសក

រាជធានីភ្នំពេញ.ថ្ងៃទី 12 ខែ [illegible] ឆ្នាំ២០០២

# សេចក្តីប្រកាស

ស្តីពី

## តំបន់អភិរក្សជីវៈចំរុះ " សីមា " ក្នុងព្រៃសម្បទាន ក្រុមហ៊ុនសាមលីញអន្តរជាតិ នៅ ខេត្តមណ្ឌលគិរី-ក្រចេះ

ដោយផ្អែកតាមលទ្ធផលចុះសិក្សាស្រាវជ្រាវរបស់នាយកដ្ឋាន រុក្ខា-ប្រមាញ់ សហការជាមួយអង្គការសមាគមអភិរក្សសត្វព្រៃប្រចាំកម្ពុជា WILDLIFE CONSERVATION SOCIETY (WCS) ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិនៅខេត្តមណ្ឌលគិរី-ក្រចេះ ចាប់តាំងពីឆ្នាំ២០០០រហូតដល់បច្ចុប្បន្នបានបង្ហាញយ៉ាងច្បាស់ថា តំបន់ព្រៃសម្បទាននេះមានសក្តានុពលខ្ពស់សំរាប់ការអភិរក្សជីវៈចំរុះ ។ ប៉ុន្តែទន្ទឹមនឹងភាពសម្បូរបែបនៃសក្តានុពលធនធានសត្វព្រៃ ជីវៈចំរុះត្រូវបានទទួលការគំរាមកំហែងយ៉ាងខ្លាំងក្លាបណ្តាលមកពី ការប្រមាញ់សត្វព្រៃ ការប្រមូលផល-អនុផលព្រៃឈើហួសកំរិត ការកាប់រានដីព្រៃដោយអនាធិបតេយ្យ ។

ដោយមើលឃើញការចាំបាច់ និង តួនាទីដ៏មានសារៈសំខាន់នៃការអភិរក្សជីវៈចំរុះ " **សីមា** " នៅក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិខេត្តមណ្ឌលគិរី-ក្រចេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចេញសេចក្តីប្រកាស ដូចតទៅ:

១-តំបន់អភិរក្សជីវៈចំរុះ " **សីមា** " ដែលមានផ្ទៃដីចំនួន ៣០៥.៤៤០ហិកតា នៅក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលិញអន្តរជាតិខេត្តមណ្ឌលគិរី-ក្រចេះ ដើម្បីរៀបចំផែនការគ្រប់គ្រងរយៈពេលវែង ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមករ : A1(702280, 1334410) , B1(708170, 1334500) , A2B2(738020, 1358890), A3(739800, 1366720) , B3(730130, 1374550) , A4(729960, 1399270) , B4(711970, 1387210) , A5(706380, 1394770) , B5(702350, 1389500) , A6(676760, 1386750) , B6(692900, 1382650) , A7(652820, 1359220) , B7(682300, 1376200) , A8(658180, 1345560) , B8(701000, 1357600) , B9(705870, 1348780) ។

២-ហាមឃាត់ដាច់ខាតរាល់សកម្មភាពកាប់រានដីព្រៃឈើ ការកាប់រំលំដើមឈើដើម្បីប្រមូលអនុផលព្រៃឈើ និង ការប្រមាញ់សត្វព្រៃ តាមបទប្បញ្ញត្តិច្បាប់ ។

៣-តំបន់អភិរក្សជីវៈចំរុះ " សីមា " ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញូអន្តរជាតិនៅខេត្តមណ្ឌលគីរី-ក្រចេះ អាចធ្វើការកែប្រែតាមការចាំបាច់ ផ្អែកលើលទ្ធផលព័ត៌មានវិទ្យាសាស្ត្រ និង ស្ថានភាពជាក់ស្តែងនៅពេលអនាគត ។

៤-តំបន់អភិរក្សជីវៈចំរុះ " សីមា " នេះ មិនប៉ះពាល់ដល់ដំណើរការគ្រប់គ្រង និង ការប្រមូលផលពីព្រៃសម្បទានរបស់ក្រុមហ៊ុនសាមលីញូអន្តរជាតិទេ ។

៥-ការរៀបចំ និង ការប្រព្រឹត្តទៅនៃតំបន់ជីវៈចំរុះ " សីមា " នេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន រុក្ខា-ប្រមាញ់ សហការជាមួយក្រុមហ៊ុនព្រៃសម្បទានសាមលីញូអន្តរជាតិ និង មានការបែងចែកភារកិច្ចដូចតទៅ:

-នាយកដ្ឋាន រុក្ខា-ប្រមាញ់ មានភារកិច្ចធ្វើការរៀបចំ និង គ្រប់គ្រងតំបន់អភិរក្សជីវៈចំរុះ " សីមា " ដោយធានានូវការអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ។

-ក្រុមហ៊ុនព្រៃសម្បទានសាមលិញូអន្តរជាតិ មានតួនាទីបង្កលក្ខណៈងាយស្រួលសហការ ឧបត្ថម្ភដល់ដំណើរការខាងលើ និង ចូលរួមចាត់វិធានការទប់ស្កាត់ និង លុបបំបាត់នូវគ្រប់រូបភាពអនាធិបតេយ្យក្នុងតំបន់អភិរក្សជីវៈចំរុះ " សីមា " នេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ក្រោយពីទទួលសេចក្តីប្រកាសនេះ គ្រប់អង្គភាពនៅថ្នាក់កណ្តាល ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តមណ្ឌលគីរី និង ខេត្តក្រចេះ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ខិតខំអនុវត្តសេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**ចាន់ សារុន**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងបរិស្ថាន
-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-សាលាខេត្តមណ្ឌលគីរី
-សាលាខេត្តក្រចេះ
-ក្រុមហ៊ុនព្រៃសម្បទានដែលមានការពាក់ព័ន្ធ
-ឯកសារ-កាលប្បវត្តិ

# តំបន់អភិរក្សជីវៈចំរុះ "សីមា" ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិ ខេត្តមណ្ឌលគីរី_ក្រចេះ






បានឃើញ និង ឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ... ឆ្នាំ ២០០២

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ